ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ០១ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៩

## I. សេចក្តីផ្តើម

១- មាត្រា ២៦ ថ្មី នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំ ផែនការយុទ្ធសាស្ត្រថវិកាពីខែ មីនា ដល់ខែ ឧសភា (២) *ដំណាក់កាលទី ២:* ការរៀបចំកញ្ចប់ថវិកា ពីខែ មិថុនា ដល់ខែ កញ្ញា និង *ដំណាក់កាលទី ៣:* ការអនុម័តថវិកា ពីខែ តុលា ដល់ខែ ធ្នូ ។ ដើម្បីធានា ការអនុវត្តច្បាប់ និង ដើម្បីបង្កើនការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែ មេសា សំរាប់ដំណាក់កាលទី ១ និង ***សារាចរណែនាំស្តីពីការរៀបចំកញ្ចប់ថវិកា*** នៅដើមខែ មិថុនា សំរាប់ដំណាក់កាលទី ២ ។ ដូច្នេះ សារាចរនេះមានគោលបំណង ដើម្បីណែនាំធ្វើជាមគ្គុទ្ទេសក៍ និង ធ្វើជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសំរាប់ឆ្នាំ ២០០៩ ដល់គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញគ្រប់ខេត្ត- ក្រុងទាំងអស់ ។

២- ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ជាពិសេស ដើម្បីបង្កើនការវិភាជន៍ថវិកាអោយចំទិសដៅ និង បំរើអោយសកម្មភាពអាទិភាពជាក់ស្តែងរបស់ក្រសួង- ស្ថាប័ន ក្នុងគោលដៅសំរេចអោយបាននូវគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួង- ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយយុទ្ធសាស្ត្រជាអាទិភាពរបស់វិស័យនីមួយៗ ដើម្បីរួមចំណែកសំរេចអោយបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** តំរូវអោយក្រសួង- ស្ថាប័ននីមួយៗ រៀបចំ និង ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** ជារៀងរាល់ឆ្នាំ ។ ផែនការយុទ្ធសាស្ត្រថវិកានេះគឺជាមូលដ្ឋានដ៏សំខាន់សំរាប់ (១) ផ្សារភ្ជាប់គោលនយោបាយ ទៅនឹងថវិកា

(២) បង្កើនសុក្រឹតភាពក្នុងការគណនាតំរូវការថវិកា (៣)ជាមូលដ្ឋានសំរាប់ពន្យល់ និងធ្វើអំណះអំណាងលើតំរូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព និងពិសេស (៥) គឺជាមូលដ្ឋានសំរាប់វាយតំលៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និង វិភាជន៍ថវិកា ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ បាន និង កំពុងក្លាយជាឧបករណ៍ និង យន្តការដ៏សំខាន់សំរាប់បង្កើនប្រសិទ្ធភាពនៃការវិភាជន៍ និង ការគ្រប់គ្រងថវិកា ជាពិសេស សំរាប់ធ្វើសមាហរណកម្ម ថវិកាចរន្ត និង ថវិកាមូលធន ទាំងថវិកាជាតិ និង ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ អោយទៅជាថវិកាមួយឯកភាព និង គ្រប់ជ្រុងជ្រោយ ។ ដើម្បីអោយការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ អាចប្រព្រឹត្តទៅដោយរលូន និង គ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តំរូវអោយផ្សារភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង បញ្ចូលទាំងចំណាយចរន្ត និង មូលធន ព្រមទាំងថវិកាជាតិ និង ថវិកាដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតក្រុមការងារថវិកា ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និង គណនេយ្យ នាយកដ្ឋានផែនការ និង គ្រប់អង្គភាពគ្រប់គ្រងគំរោង ។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង និង វិស័យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ពិនិត្យសំរេច និងចុះហត្ថលេខា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបាន ***ត្រឹមថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨*** ដើម្បីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់សំរាប់ពិនិត្យ និង អាចអញ្ជើញតំណាងក្រសួងសាមីមកពិគ្រោះ និង សាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់ ។ ក្រសួង-ស្ថាប័ន ដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិ វិភាជន៍កញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និង ការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

៤- សេដ្ឋកិច្ចកម្ពុជា កំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ហើយឈានទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និង សេវាកម្ម ធៀបនឹងកសិកម្ម នៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស)។ ជាក់ស្តែង ទោះជាផលិតភាពនៃវិស័យកសិកម្មបាន និង បន្តកើន តែកំនើននៃវិស័យឧស្សាហកម្ម និង សេវាកម្ម បានកើនឡើងលឿនជាង ដែលមកដល់ឆ្នាំ ២០០៧ កន្លងទៅនេះ ធ្វើអោយការរួមចំណែកនៃវិស័យកសិកម្ម ថយចុះមកនៅស្មើនឹងវិស័យឧស្សាហកម្មគឺ ២៧% រីឯវិស័យសេវាកម្មឡើងដល់ ៣៩% ។ ទោះបីសមាមាត្រនៃវិស័យកសិកម្មនៅក្នុង ផសស ចាប់ផ្តើមធ្លាក់ចុះជាបន្តបន្ទាប់ក៏ដោយ ក៏វិស័យនេះ

នៅតែមានសក្តានុពលខ្ពស់ក្នុងការជំរុញ និង ពង្រីកកំណើនសេដ្ឋកិច្ច ក្នុងការជួយកាត់បន្ថយភាពក្រីក្រ នៅជនបទដែលជាអាទិភាពខ្ពស់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។ ប្រការនេះ បញ្ជាក់អោយឃើញថា ការបង្កើនទិន្នផល និង ផលិតភាពកសិកម្ម និង ការជំរុញការអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ជាពិសេស កសិ-ឧស្សាហកម្ម សហគ្រាសធុនតូច និង មធ្យម ពាណិជ្ជកម្ម និងសេវាកម្ម នៅតែជាយុទ្ធសាស្ត្រសំខាន់ និងចាំបាច់ ដើម្បីបង្កើនតំលៃបន្ថែមលើផលិតផល និងស្រូបយកពលកម្ម ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និង ដើម្បីពង្រីកមូលដ្ឋាននៃកំណើន រក្សាចីរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ច ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេលមធ្យម (២០០៩-២០១១) សេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យម ប្រមាណពី ៦% ទៅ ៧% ស្របតាមគោលដៅ **យុទ្ធសាស្ត្រចតុកោណ** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។

**៥-** ឆ្នាំ ២០០៨ នេះ តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានប្រមាណ ៧,២% គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ (៧%) តែទាបជាងការអនុវត្តបានជាក់ស្តែងក្នុងឆ្នាំ ២០០៧ (៩,៧%) កន្លងទៅ ។ នេះជាសេណារីយ៉ូប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេសដោយសារការរងឥទ្ធិពលនៃការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន និង កត្តាអតិផរណាថវិកា អតិផរណាទីផ្សារ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ។ ទោះជាយ៉ាងណាក៏ដោយ វិស័យសំខាន់ៗនៃខឿនសេដ្ឋកិច្ចកម្ពុជា នឹងនៅតែបន្តកើនឡើង ទោះជាល្បឿននៃកំនើននៃវិស័យខ្លះអាចថយចុះបន្តិចក៏ដោយ ។ តាមសេណារីយ៉ូនេះ វិស័យឧស្សាហកម្មនឹងមានកំណើនត្រឹមប្រមាណ ៦% ធៀបនឹង ៧,៥% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងមានកំណើនត្រឹមប្រមាណ ៥% ធៀបនឹង ១០% នៅក្នុងឆ្នាំ ២០០៧ ហើយផលិតផលសំណង់ នឹងមានកំណើនត្រឹមប្រមាណ ៦% ធៀបនឹង ៦,៧% នៅក្នុងឆ្នាំ ២០០៧) វិស័យសេវាកម្ម នឹងមានកំណើនប្រមាណ ១០% ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍ នឹងមានកំណើនប្រមាណ ១០% ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧) ។

**៦-** តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៩ ខាងមុខនេះ អាចនឹងសំរេចបានប្រមាណ ៧% ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៨ នេះដែរ ។ ទោះជាត្រូវទទួលឥទ្ធិពលពីខាងក្រៅដូចជា ការធ្លាក់ចុះនៃសេដ្ឋកិច្ចអាមេរិក និង ការប្រឈមនឹងការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និង ចិន ក៏ដោយ ក៏កំណើននៃតំរូវការក្នុងស្រុក និងលំហូរចូលនៃមូលនិធិពីក្រៅប្រទេសនឹងនៅតែបន្តកើនឡើងគ្រប់គ្រាន់ សំរាប់រក្សាកំណើនមិនអោយធ្លាក់ចុះក្រោម ៧% ដែរ ។ ជាពិសេស វិស័យកសិកម្មនឹងនៅតែកើនឡើងប្រមាណ ៤,៥% ដែលក្នុងនោះ

ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៥% វិស័យឧស្សាហកម្មនឹងកើនឡើង ៦,៥% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៦% និង ផលិតផលសំណង់នឹងកើនឡើង ៨,៥% និង វិស័យសេវាកម្មនឹងកើនឡើង ៩% ដែលក្នុងនោះ អាជីវកម្មទេសចរណ៍នឹងកើនឡើងប្រមាណ ១០% ។

៧- អតិផរណានៅចុងឆ្នាំ ២០០៧ បានឡើងដល់ ១០,៨% ទោះជាមធ្យមភាគប្រចាំឆ្នាំស្ថិតនៅត្រឹមប្រមាណ ៦% ក៏ដោយ ដែលធ្វើអោយសាធារណជនមានការព្រួយបារម្ភ ។ ប្រការនេះគឺដោយសារកត្តាឥទ្ធិពលពីខាងក្រៅធំៗ បីជាមូលដ្ឋាន (១) កត្តាថ្លៃស្បៀងលើពិភពលោកកើនឡើងខ្លាំងដោយសារកំណើននៃតំរូវការរបស់ប្រទេសចិន និង ការធ្វើប្រេងជីវសាស្ត្ររបស់សហរដ្ឋអាមេរិក (២) កត្តាថ្លៃប្រេងលើទីផ្សារពិភពលោកឡើងថ្លៃ (៣) កត្តាដុល្លារអាមេរិកចុះថ្លៃ ដែលធ្វើអោយរូបិយប័ណ្ណបរទេសមួយចំនួនឡើងថ្លៃ ហើយនាំអោយថ្លៃទំនិញនាំចូលពីប្រទេសទាំងនោះឡើងថ្លៃ ។ ទន្ទឹមនឹងនេះ កត្តាកំណើនតំរូវការក្នុងស្រុកក៏បានរួមចំណែកក្នុងការធ្វើអោយថ្លៃទំនិញមួយចំនួនឡើងថ្លៃដែរ ជាពិសេស ម្ហូបអាហារ និងសំភារៈប្រើប្រាស់ ដោយសារចំណូលរបស់ប្រជាជនកើនឡើង និង កំណើនទេសចរណ៍ ។ តាមការព្យាករណ៍អតិផរណាជាមធ្យមនៅឆ្នាំ ២០០៨ នេះអាចឡើងដល់ប្រមាណ ៧,៥% ប៉ុន្តែនៅឆ្នាំ ២០០៩ ខាងមុខអាចនឹងធ្លាក់មកនៅត្រឹមរង្វង់ ៥% ដោយសង្ឃឹមថាកត្តាឥទ្ធិពលពីខាងក្រៅទាំង ៣ ខាងលើនឹងត្រឡប់មករកភាពធូរស្រាលវិញ ។

## ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

៨- ទោះជាឆ្នាំ ២០០៨ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសំរេចបានទាបជាងឆ្នាំ ២០០៧ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ពិសេសលើការអនុវត្តថវិកាឡើយ ព្រោះកំណើន ៧,២% នេះ ប្រហាក់ប្រហែលទៅនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៨ (៧%) ហើយការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និង ប្រុងប្រយ័ត្នខ្ពស់ គួបផ្សំជាមួយនឹងការអនុវត្តកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ជាជំហានៗ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និង ទៅតាមលំដាប់លំដោយត្រឹមត្រូវនិងច្បាស់លាស់ នោះនឹងមិនត្រឹមតែធ្វើអោយការអនុវត្តថវិកាឆ្នាំ ២០០៨ សំរេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុប៉ុណ្ណោះទេ តែថែមទាំងអាចនឹងមានលក្ខណៈល្អប្រសើរជាងឆ្នាំ ២០០៧ ទៀតផង ។ តាមការព្យាករណ៍ ចំណូលសរុបនឹងកើនឡើងប្រមាណ ១៤,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៧ គឺចំណូលក្នុងស្រុកសរុប នឹងសំរេចបាន ១១,៥% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៩,៨% នៃផសស (ចំណូលគយ និងរដ្ឋាករ ស្មើនឹង ៥,៧% និង ចំណូលពន្ធដារស្មើនឹង ៣%) ចំណូលមិនមែន សារពើពន្ធនឹងសំរេចបាន ១,៦% នៃផសស ។ ចំណាយសរុបអាចនឹងសំរេចបាន ១៤,៤% នៃផសស កើនឡើងជិត ២% នៃផសស ធៀបនឹងឆ្នាំ ២០០៧ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៩% នៃផសស កើនឡើង ១,៤% នៃផសស ធៀបនឹងឆ្នាំ ២០០៧ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៤% នៃផសស

ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧ ។ ការអនុវត្តចំណូល និង ចំណាយនេះ អាចនឹងធ្វើអោយមាន អតិរេកចរន្ត ប្រមាណ ២% និង ឱនភាពថវិកាសរុបប្រមាណ ៣,៨% នៃផសស ។

៩- ដោយឈរលើមូលដ្ឋាននៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាល គួបផ្សំនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ថវិកាឆ្នាំ ២០០៩ មានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស ការបន្តជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ***ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*** របស់រាជរដ្ឋាភិបាល ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (PIP) ។
- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដូចជាៈ
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និង សុខាភិបាល ។
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍន៍ជនបទ ។
- ធានាការបន្តអនុវត្តកម្មវិធីកំណែទំរង់ និង អភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ កម្មវិធីកំណែទំរង់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ កម្មវិធីកំណែទំរង់កងទ័ព កម្មវិធីកំណែទំរង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កម្មវិធីអភិវឌ្ឍន៍ផ្នែកឯកជន និង ការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ។

១០- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅទាំងអស់នេះ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៩ ត្រូវគ្រោង និង រៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តអោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១២%នៃផសស គឺមានកំណើន ០,៥% នៃផសស ធៀបនឹងឆ្នាំ ២០០៨ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសំរេច

អោយបាន ១០,៧% នៃផសស គឺមានកំណើន ០,៣% នៃផសស ធៀបនឹងឆ្នាំ ២០០៨ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ១,៦% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៨ ។

• បន្តពង្រឹងការរៀបចំថវិកា អោយកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និង សុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមអោយបានច្បាស់លាស់ និង សុក្រឹត ការធ្វើសមាហរណកម្មថវិកា និង ការអនុវត្តថវិកាតាមកម្មវិធី ។

• បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និង ជំរុញការកែលំអការអនុវត្តថវិកា តាមរយៈការកាត់បន្ថយនីតិវិធីចំណាយ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ និង ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសំរេចបាននៅក្នុងជំហានទី១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ សំរាប់ការឈានទៅជំហានទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និង បណ្តាជំហានបន្តបន្ទាប់ទៀត ។

• បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និង ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ អោយកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និង ជាពិសេស ឈានទៅកំណត់ និងដាក់អោយអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថ និងនីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដ៏ចំបងសំរាប់សំរេចជំហានទី២ គឺ ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

• បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៩,៥% នៃផសស គឺកើនឡើង ប្រមាណ ១,៥% នៃផសស ដែលក្នុងនោះ ចំណាយចរន្តនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ១០% និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៩,៥% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្ត ក្នុងរង្វង់ ១,៧% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៤% នៃផសស ។

• បន្តផ្តល់អាទិភាព និង ជំរុញការរៀបចំថវិកាតាមកម្មវិធី និង ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស បន្តពិនិត្យលទ្ធភាពដើម្បីបង្កើនការសាកល្បងការអនុវត្តថវិកាតាមកម្មវិធី តាមរយៈការបង្កើនទំហំថវិកាកម្មវិធី និង ពង្រីកការអនុវត្តន៍ទៅក្រសួងផ្សេងទៀតក្រៅពីក្រសួង-៨ ដែលបាន និង កំពុងអនុវត្តនៅក្នុងឆ្នាំ ២០០៨ នេះ (ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកិច្ចការនារី និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ។

- បន្តផ្តល់អាទិភាពលើកិច្ចការវិនិយោគសាធារណៈ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានផ្លូវ ស្ពាន ប្រព័ន្ធស្រោចស្រព និង ការវិនិយោគលើការលើកកំពស់ផលិតភាពកសិកម្ម ។

## III. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១១- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០០៨-២០១០ របស់ខ្លួន និង ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង-ស្ថាប័ននីមួយៗត្រូវត្រួតពិនិត្យឡើងវិញ និងវាយតំលៃលើការអនុវត្តកន្លងមក ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០០៩-២០១១ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។ គំរូផែនការយុទ្ធសាស្ត្រថវិកា ២០០៩-២០១១ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះរួមមាន ៥ ផ្នែកគឺៈ

***ផ្នែកទី ១: មុខងារ និងភារកិច្ច*** គឺជាការបញ្ជាក់អំពីមុខងារ ភារកិច្ច និង ការទទួលខុសត្រូវរួមរបស់ក្រសួង-ស្ថាប័ន ដែលបានកំណត់ និងប្រគល់ដោយរាជរដ្ឋាភិបាល ។

***ផ្នែកទី ២: ទិសដៅគោលនយោបាយ*** គឺជាទិសដៅគោលនយោបាយរយៈពេលមធ្យម (ពី ៣ ទៅ ៥ ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង-ស្ថាប័ន ដើម្បីអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួនដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ជាពិសេស ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និង លើកកំពស់ការជីវភាពរបស់ប្រជាពលរដ្ឋ ។

***ផ្នែកទី ៣: កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាព និង តំរូវការធនធាន*** គឺជាកម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាពដែលកំណត់ដោយក្រសួង-ស្ថាប័ន ដើម្បីអនុវត្ត និងសំរេចអោយបាននូវទិសដៅគោលនយោបាយរយៈពេលមធ្យមដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងលើ ។ កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវគណនាតំរូវការធនធានអោយបានច្បាស់លាស់ ទៅតាមឆ្នាំ ប្រភេទចំណាយ និង ប្រភពធនធាន ដូចក្នុងតារាងទី ៣.១ និង ៣.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៤: ការគ្រោង និង ព្យាករណ៍ចំណូល*** គឺជាការគ្រោង និង ព្យាករណ៍ចំណូលសំរាប់រយៈពេល ៣ ឆ្នាំ (២០០៩-២០១០) របស់ក្រសួង-ស្ថាប័នដែលមានភារកិច្ចប្រមូលចំណូលដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និង បទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និង វិធានការថ្មីដែលគ្រោងនឹងដាក់អោយអនុវត្ត ។ ការគ្រោង និង ព្យាករណ៍ចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទ

នៃចំណូលទាំងអស់ រួមទាំងចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍សំរាប់អនុវត្តគំរោងនៅក្នុងក្រសួង-ស្ថាប័ន ផងដែរ ។

***ផ្នែកទី ៥: ការកំណត់សូចនាករ និង គោលដៅ*** គឺជាការកំណត់សូចនាករ និង គោលដៅសំរាប់វាស់លទ្ធផលសំរេចបានទៅតាមកម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាព ដែលក្រសួង-ស្ថាប័នបានកំណត់ ដើម្បីសំរេចបាននូវគោលដៅនៃទិសដៅគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលនឹងរួមចំណែកក្នុងការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាល ។ សូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និង កំណត់គោលដៅនៃលទ្ធផលចុងក្រោយ ព្រមទាំងបញ្ជាក់ថាតើសូចនាករនីមួយៗ ឆ្លើយតបទៅនឹង កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាព និង ទិសដៅគោលនយោបាយណាមួយ ដូចក្នុងតារាងទី ៥.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។

១២- ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ត្រូវអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណី ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា អោយបានទាន់ពេលវេលាតាមកាលកំណត់ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ ២០០៨*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

***"ដើម្បីជូនជ្រាប"***

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

***"ដើម្បីមុខការ"***

- ឯកសារ-កាលប្បវត្តិ

(គំរូរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយនឹងសារាចរណែនាំ)

# ផែនការយុទ្ធសាស្ត្រថវិកា
# សំរាប់ឆ្នាំ ២០០៩ ~ ២០១១
# របស់ក្រសួង/ស្ថាប័ន.................

## I. មុខងារ និងភារកិច្ច

ក្រសួង/ស្ថាប័ន........ មានតួនាទីដ៏សំខាន់ក្នុងការនាំមកនូវ.................................................... ។

## II. ទិសដៅគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិលើកទី ២ ឆ្នាំ ២០០៦~២០១០** និង ជាពិសេសការបន្តជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** របស់រាជរដ្ឋាភិបាលសំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និង លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង/ស្ថាប័ន........មានទិសដៅគោលនយោបាយដូចខាងក្រោមៈ

ទិសដៅគោលនយោបាយទី ១ :.........................................................................................

ទិសដៅគោលនយោបាយទី ២ :.........................................................................................

ទិសដៅគោលនយោបាយទី ៣ :.........................................................................................

ទិសដៅគោលនយោបាយទី ៤ :.........................................................................................

ទិសដៅគោលនយោបាយទី ៥ :.........................................................................................

## III. កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព និងតំរូវការធនធាន

ដើម្បីអនុវត្តទិសដៅគោលនយោបាយខាងលើអោយទទួលបានជោគជ័យ ក្រសួង/ស្ថាប័ន បានរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព និងបានកំណត់ពីតំរូវការធនធានដោយផ្អែកលើទិសដៅគោលនយោបាយ កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និង ផ្អែកលើបទពិសោធន៍អនុវត្តក្នុងឆ្នាំកន្លងមក រួមទាំងការសន្សំ សំចៃដើម្បីប្រសិទ្ធភាពថវិកា ដែលមានដូចខាងក្រោមៈ

## តារាងទី ៣.១ : កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពសំរាប់ឆ្នាំ ២០០៩ ~ ២០១១

ឯកតា:លានរៀល

| ទិសដៅគោលនយោបាយ | កម្មវិធី ឬ/និង យុទ្ធសាស្ត្រអាទិភាព | រយៈពេលអនុវត្ត | តំរូវការឥណទានសរុប | ឥណទានបានអនុវត្តកន្លងមក | ព្យាករណ៍ | | | តំរូវការឥណទានបន្ត |
|---|---|---|---|---|---|---|---|---|
| | | | | | ២០០៩ | ២០១០ | ២០១១ | |
| ទិសដៅគ.ប ទី ១: ........................ | ១.១:........................................ | | | | | | | |
| | ១.២:........................................ | | | | | | | |
| | ១.៣:........................................ | | | | | | | |
| ទិសដៅគ.ប ទី ២: ........................ | ២.១:........................................ | | | | | | | |
| | ២.២:........................................ | | | | | | | |
| | ២.៣:........................................ | | | | | | | |
| ទិសដៅគ.ប ទី ៣: ........................ | ៣.១:........................................ | | | | | | | |
| | ៣.២:........................................ | | | | | | | |
| | ៣.៣:........................................ | | | | | | | |
| ទិសដៅគ.ប ទី ៤: ........................ | ៤.១:........................................ | | | | | | | |
| | ៤.២:........................................ | | | | | | | |
| | ៤.៣:........................................ | | | | | | | |
| ទិសដៅគ.ប ទី ៥: ........................ | ៥.១:........................................ | | | | | | | |
| | ៥.២:........................................ | | | | | | | |
| | ៥.៣:........................................ | | | | | | | |

**តារាងទី ៣.២ : ការគ្រោង និងព្យាករណ៍ចំណាយសំរាប់ឆ្នាំ ២០០៩ - ២០១១**

ឯកតា:លានរៀល

| ទិសដៅគោលនយោបាយ/កម្មវិធី/យុទ្ធសាស្ត្រអាទិភាព/ប្រភេទចំណាយ | ច្បាប់ ឆ្នាំ ២០០៨ | | | គ្រោង ឆ្នាំ ២០០៩ | | | ព្យាករណ៍ ឆ្នាំ ២០១០ | | | ព្យាករណ៍ ឆ្នាំ ២០១១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| **សរុបរួម** | | | | | | | | | | | | |
| -ចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -ចំណាយមូលធន | | | | | | | | | | | | |
| **១. ទិសដៅគ.ន ទី ១** | | | | | | | | | | | | |
| ១.១:កម្មវិធី/យុទ្ធសាស្ត្រទី ១ | | | | | | | | | | | | |
| -ចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -ចំណាយមូលធន | | | | | | | | | | | | |
| ១.២:កម្មវិធី/យុទ្ធសាស្ត្រទី ២ | | | | | | | | | | | | |
| -.................. | | | | | | | | | | | | |
| **២. ទិសដៅគ.ន ទី ២** | | | | | | | | | | | | |
| ២.១:កម្មវិធី/យុទ្ធសាស្ត្រទី ១ | | | | | | | | | | | | |
| -ចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -ចំណាយមូលធន | | | | | | | | | | | | |
| ២.២:កម្មវិធី/យុទ្ធសាស្ត្រទី ២ | | | | | | | | | | | | |
| -.................. | | | | | | | | | | | | |
| **៣. ទិសដៅគ.ន ទី ៣** | | | | | | | | | | | | |
| ៣.១:.................. | | | | | | | | | | | | |

## IV. ការគ្រោង និងព្យាករណ៍ចំណូល

ដើម្បីរួមចំណែកដល់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលធនធានដើម្បីសំរេចឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ក្រសួង/ស្ថាប័ន បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនដើម្បីពង្រឹងការប្រមូល ចំណូលដូចខាងក្រោម:

ក.................................................

ខ.................................................

គ.................................................

តាមរយៈយុទ្ធសាស្ត្រនេះ ក្រសួង/ស្ថាប័ន រំពឹងថាចំណូលនៅក្នុងរយៈពេល ០៣ ឆ្នាំ នឹងកើនឡើងដូចខាងក្រោម:

**តារាងទី ៤.១ : ការគ្រោង និងព្យាករណ៍ចំណូល**
**សំរាប់ឆ្នាំ ២០០៩ - ២០១១**

ឯកតា:លានរៀល

| ចំណូល តាមជំពូក-គណនី-អនុគណនី | ច្បាប់ ឆ្នាំ ២០០៨ | គ្រោង ឆ្នាំ ២០០៩ | ព្យាករណ៍ ឆ្នាំ ២០១០ | ព្យាករណ៍ ឆ្នាំ ២០១១ |
|---|---|---|---|---|
| **សរុបចំណូល** | | | | |
| ១.ចំណូលសារពើពន្ធ | | | | |
| ២.ចំណូលមិនមែនសារពើពន្ធ | | | | |
| ២. ចំណូលមូលធន (ហិរញ្ញប្បទានពីបរទេស)<br>គំរោង/កម្មវិធី.................<br>គំរោង/កម្មវិធី................. | | | | |

## V. ការកំណត់សូចនាករ និងគោលដៅ

នៅក្នុងការអនុវត្តចំណាយដូចបានគ្រោងខាងលើ ក្រសួង/ស្ថាប័ន បានកំណត់នូវសូចនាករ និងគោលដៅ ដើម្បីអនុវត្តដូចខាងក្រោម:

**តារាងទី ៥.១: សូចនាករ និងគោលដៅ**

| សូចនាករ | កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | ស្ថានភាពបច្ចុប្បន្នរបស់សូចនាករ | គោលដៅនៃលទ្ធផលក្នុងឆ្នាំ (Output Target) | | | គោលដៅនៃលទ្ធផលចុងក្រោយ (Outcome Target) |
|---|---|---|---|---|---|---|
| | | | ឆ្នាំ ២០០៩ | ឆ្នាំ ២០១០ | ឆ្នាំ ២០១១ | |
| សូចនាករទី ១......... | កម្មវិធី/យុទ្ធសាស្ត្រអាទិភាពទី......<br>..........................<br>.......................... | | | | | |
| សូចនាករទី ២......... | កម្មវិធី/យុទ្ធសាស្ត្រអាទិភាពទី......<br>..........................<br>.......................... | | | | | |
| សូចនាករទី ៣......... | កម្មវិធី/យុទ្ធសាស្ត្រអាទិភាពទី......<br>..........................<br>.......................... | | | | | |
| សូចនាករទី ៤......... | កម្មវិធី/យុទ្ធសាស្ត្រអាទិភាពទី......<br>..........................<br>.......................... | | | | | |
| សូចនាករទី ៥......... | កម្មវិធី/យុទ្ធសាស្ត្រអាទិភាពទី......<br>..........................<br>.......................... | | | | | |